# ចំណេះចំណានខាងគោលលទ្ធិនៃព្រះគម្ពីរសញ្ញាថ្មី ៖ ការវាយតម្លៃទី១

សៀវភៅសិក្សាព្រះគម្ពីរសញ្ញាថ្មីសម្រាប់ថ្នាក់សិក្ខាសាលា

## សេចក្តីយោងចំណេះចំណានខាងគោលលទ្ធិ

សម្រាប់សំណួរ ទី ១–៣ សូមសរសេរអក្សរនៃសេចក្តីយោងដែលត្រូវគ្នាក្នុងចន្លោះទទេនៅជាប់នឹងឃ្លានីមួយៗ ។ សូមកុំប្រើព្រះគម្ពីររបស់អ្នកដើម្បីធ្វើការវាយតម្លៃនៅផ្នែកនេះឡើយ ។

១. ______ « បើមិនបានកើតអំពីទឹក ហើយអំពីព្រះវិញ្ញាណ នោះគ្មានអ្នកណាអាចនឹងចូលទៅក្នុងនគរព្រះបានទេ » ។

២. ______ ព្រះយេស៊ូវគ្រីស្ទបានបង្គាប់ថា ចូរទទួលទានសាក្រាម៉ង់ « ដើម្បីរំឭកពីខ្ញុំចុះ » ។

៣. ______ « អស់អ្នកដែលនឿយព្រួយ ហើយផ្ទុកធ្ងន់អើយ ចូរមកឯខ្ញុំ ខ្ញុំនឹងឲ្យអ្នករាល់គ្នាឈប់សម្រាក » ។

ក. ម៉ាថាយ ១១:២៨–៣០

ខ. លូកា ២:១០–១២

គ. លូកា ២២:១៩–២០

ឃ. យ៉ូហាន ៣:៥

ង. យ៉ូហាន ៣:១៦

## ឃ្លាបទគម្ពីរគន្លឹះ

សម្រាប់សំណួរទី ៤–៦ សូមបំពេញពាក្យដែលបាត់ក្នុងឃ្លាបទគម្ពីរគន្លឹះចំណេះចំណានខាងគោលលទ្ធិ ។ សូមកុំប្រើព្រះគម្ពីររបស់អ្នកដើម្បីធ្វើការវាយតម្លៃនៅផ្នែកនេះឡើយ ។

៤. ព្រះយេស៊ូវបានមានបន្ទូលថា « ខ្ញុំនឹង ______________ នៃ ______________ ដល់អ្នក » ។ ( ម៉ាថាយ ១៦:១៥–១៩ )

៥. « ដ្បិតនៅថ្ងៃនេះ មាន______________ មួយអង្គ ______________ ដល់អ្នករាល់គ្នានៅក្រុងហ្លួងដាវីឌ គឺជាព្រះគ្រីស្ទដ៏ជា______________ » ។ ( លូកា ២:១០–១២ )

៦. « ដ្បិត______________ គ្មាន______________ ឬ ______________ ដូចជាឃើញខ្ញុំនេះទេ » ។ ( លូកា ២៤:៣៦–៣៩ )

អ្នកអាចប្រើប្រាស់ព្រះគម្ពីររបស់អ្នកសម្រាប់ការវាយតម្លៃដែលនៅសល់ ។

សម្រាប់សំណួរទី ៧–៩ សូមរកមើលវគ្គចំណេះចំណានខាងគោលលទ្ធិមួយ ឬច្រើនដែលអាចជួយនរណាម្នាក់ក្នុងស្ថានភាពដូចខាងក្រោម ។

| | | |
|---|---|---|
| ៧. | អ្នកនៅជាមួយពួកអ្នកផ្សព្វផ្សាយសាសនា នៅពេលមានបុគ្គលម្នាក់សួរថា តើពួកគេពិតជាត្រូវការទទួលបុណ្យជ្រមុជទឹក ឬក៏ពួកគេអាចគ្រាន់តែទទួលយកព្រះយេស៊ូវគ្រីស្ទនៅក្នុងចិត្តរបស់ពួកគេទៅបានហើយ ។ | |
| ៨. | នៅក្នុងថ្នាក់សាលាថ្ងៃអាទិត្យ មានសមាជិកនៅវួដរបស់អ្នកម្នាក់សួរថា តើពួកគេអាចដឹងថាគោលលទ្ធិដែលបានបង្រៀននៅក្នុងសាសនាចក្របានមកពីព្រះដោយរបៀបណា ។ | |
| ៩. | មានបុគ្គលម្នាក់កំពុងរៀបចំមេរៀនសម្រាប់រាត្រីជួបជុំក្រុមគ្រួសារ អំពីរបៀបដែលយើងអាចក្លាយជាសិស្សដ៏ប្រសើររបស់ព្រះយេស៊ូវគ្រីស្ទ ។ | |

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

© ២០២២ by Intellectual Reserve, Inc. All rights reserved. កំណែ ៖ ២/២១ ។ ការបកប្រែនៃ *New Testament Doctrinal Mastery: Assessment 1.*
Cambodian ។ PD60012661 258. Printed in the United States of America.

នៅក្នុងសំណួរទី ១០–១១ សូមបង្ហាញចំណេះដឹងរបស់អ្នកអំពីសមត្ថភាពក្នុងការប្រើប្រាស់គោលការណ៍នៃការទទួលបានចំណេះដឹងខាងវិញ្ញាណ ។

១០. តើអ្នកនឹងពន្យល់ពីគោលការណ៍នៃការទទួលបានចំណេះដឹងខាងវិញ្ញាណបីខាងក្រោមដល់បុគ្គលម្នាក់ ដែលមិនស្គាល់គោលការណ៍ទាំងនោះដោយរបៀបណា ?

ក. ធ្វើសកម្មភាពដោយសេចក្ដីជំនឿ

ខ. ពិនិត្យមើលគោលគំនិត និងសំណួរទាំងឡាយដោយទស្សនវិស័យដ៏នៅអស់កល្បជានិច្ច

គ. ស្វែងរកការយល់ដឹងបន្ថែមតាមរយៈប្រភពដែលបានតែងតាំងដ៏ទេវភាព

១១. អ្នកមានមិត្តម្នាក់ដែលកំពុងពុះពារនៅក្នុងការជឿថា ព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទស្រឡាញ់នាង ហើយសព្វព្រះទ័យក្នុងការប្រាស្រ័យទាក់ទងជាមួយនាង ។ សូមឆ្លើយសំណួរខាងក្រោមនេះ ៖

ក. តើរឿងជាក់លាក់អ្វីខ្លះដែលអ្នកនឹងអញ្ជើញនាងឲ្យធ្វើ ដើម្បីធ្វើសកម្មភាពដោយសេចក្ដីជំនឿ ?

ខ. តើអ្នកអាចជួយនាងឲ្យមើលឃើញស្ថានភាពរបស់នាងជាមួយនឹងទស្សវិស័យដ៏នៅអស់កល្បជានិច្ចយ៉ាងដូចម្ដេច ?

គ. វគ្គបទគម្ពីរចំណេះចំណានខាងគោលលទ្ធិគឺជាឧទាហរណ៍នៃប្រភពដែលបានតែងតាំងដ៏ទេវភាព ។ តើវគ្គបទគម្ពីរចំណេះចំណានខាងគោលលទ្ធិ ( នានា ) អ្វីខ្លះដែលអ្នកអាចចែកចាយជាមួយនាង ? ហេតុអ្វី ?

១២. ក្នុងចំណោមវគ្គបទគម្ពីរចំណេះចំណានខាងគោលលទ្ធិទាំង ១១ ដែលអ្នកបានសិក្សារួចកន្លងមក តើវគ្គបទគម្ពីរណាមួយដែលជះឥទ្ធិពលលើអ្នកច្រើនបំផុត ហើយហេតុអ្វី ? តើវគ្គបទគម្ពីរនេះបង្រៀនអ្នកអ្វីខ្លះអំពីព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទ ?

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

© ២០២២ by Intellectual Reserve, Inc. All rights reserved. កំណែ ៖ ២/២១ ។ ការបកប្រែនៃ *New Testament Doctrinal Mastery: Assessment 1*. Cambodian ។ PD60012661 258. Printed in the United States of America.